ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខនស/រកត/០៩៩៥ /៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវ ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលរឹបអូសបាននៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ មានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **នេត សាវឿន** អនុប្រធានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក **លូ រ៉ាមីន** អគ្គលេខាធិការ នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុប្រធាន

| | | |
|---|---|---|
| ៣- ឯកឧត្តម **អ៊ឹង គន្ធាផុន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៤- ឯកឧត្តម **ម៉ិន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម **ខៀវ មុត** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៦- ឯកឧត្តម **សាត សាមី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុំ សុជាតិ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក **នេត សាវឿន** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩- ឯកឧត្តម **កង ខៀង** | អភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ១០- ឯកឧត្តម ឧត្តមសេនីយ៍ទោ **ម៉ុក ជីតូ** | អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ និងនាយកមន្ទីរប្រឆាំងគ្រឿងញៀន | សមាជិក |
| ១១- លោក **គីម សោភ័ណ** | ចៅក្រម ក្រសួងយុត្តិធម៌ | សមាជិក |
| ១២- លោកឧត្តមសេនីយ៍ត្រី **ទូច ណារ៉ុថ** | ស្នងការនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ១៣- លោកវរៈសេនីយ៍ឯក **កែវ ពិសី** | ស្នងការនគរបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ១៤- លោក **មាស វិរិទ្ធ** | ប្រធានមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ១៥- លោក **ឃុត សុភាព** | ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ស្ពឺ | សមាជិក |
| ១៦- លោក **ដួង ស៊ុនណារ៉ា** | ប្រធានស្តីទី នាយកដ្ឋានអនុវត្តច្បាប់ | សមាជិក |

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាខេត្តកំពង់ស្ពឺ សាលាក្រុងភ្នំពេញ និងសាមីខ្លួនមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ